ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៖ ៤៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួល

## ផ្លាកសញ្ញារូបហនុមាន សញ្ញាកងឯកភាពធំត្រួយោង ឯកសណ្ឋានការងារលេខ៤ ម្ជុលខោនណេ ការស្លៀកពាក់ឯកសណ្ឋានការងារលេខ៤ និងសញ្ញាអគ្គបញ្ជាការ កងទ័ពជើងគោក ជើងទឹក ជើងអាកាស និង រូបសញ្ញាក្រសួងការពារជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ ន.ស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ន.ស/រកត/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ

- បានឃើញព្រះរាជក្រឹត្យលេខ ន.ស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំឯកសណ្ឋាន ផ្លាកសញ្ញា និងទង់ជ័យ នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០០០ ស្តីពីវិសោធនកម្ម អនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ១៩៩៧ ត្រង់មាត្រា ១-២-៣ និង ៨ ពាក់ព័ន្ធនឹងឯកសណ្ឋានកងទ័ពជើងគោក កងនាវាចរ កងអាកាសចរ ឯកសណ្ឋានព្រៃទ័ព និងកងកិត្តិយស
- បានឃើញអនុក្រឹត្យលេខ ៨៦អនក្រ.បក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០០១ ស្តីពីការកែសំរួល បង្កើតផ្លាកសញ្ញាមួយចំនួន បំពេញបន្ថែមលើមាត្រា ៦ នៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំឯកសណ្ឋាន ផ្លាកសញ្ញា និងទង់ជ័យ នៃកងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

## សំរេច

**មាត្រា ១.__**

ផ្លាកសញ្ញារូបហនុមាន សញ្ញាកងឯកភាពឆ័ត្រយោង ឯកសណ្ឋានការងារ(លេខ២៤) មួកបេរេ សញ្ញាអគ្គបញ្ជាការ កងទ័ពជើងគោក កងទ័ពជើងទឹក កងទ័ពជើងអាកាស និងសញ្ញាក្រសួងការពារជាតិ ត្រូវបានកែសម្រួលដូចតទៅ ÷

**១. ផ្លាកសញ្ញារូបហនុមាន** ធ្វើរាងមេដៃ ពាក់បន្ទោងនៅឡេវហោប៉ៅអាវស្តាំ ផ្លាកសញ្ញាធ្វើអំពីលោហធាតុ ផ្នែកខាងលើ មានម្កុដពណ៌មាស មានកាំរស្មីប្រាំពីរ សង្វាងមានរំយោលម្ខាងបីពណ៌មាស (តំណាងឱ្យទង់ជាតិ) ផ្នែកកណ្តាល ពណ៌ទឹកប៊ិច លើផ្ទៃកណ្តាលមានរូបហនុមានកាន់ព្រះខ័ន្ធ កំពុងសំដែងឫទ្ធិ ពណ៌ស្វាទុំ នៅផ្នែកខាងក្រោមមាន ជើងពានរាងដូចស្លែងក្របី ផ្ទៃពណ៌ក្រហម រឹមជុំវិញ ពណ៌មាស នៅលើផ្ទៃនោះសរសេរអក្សរកាត់ថា (ខ.ភ.ម ) ពណ៌មាស ។ រូបភាពនៃរូបសញ្ញាហនុមានថ្មីមានដូចក្នុងឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យនេះ ។

**ខ្នាត** : - កំពស់រូបភាព ៦០ ម.ម ទទឹង ៤៥ ម.ម
- កំពស់ម្កុដ ២៧ ម.ម បាតក្រោមម្កុដ ៣៤ ម.ម
- ផ្ទៃពណ៌ខៀវកណ្តាល កំពស់ ៣២ ម.ម ទទឹង ៣០ ម.ម ហនុមាន កំពស់ ២៤ ម.ម ទទឹង ២៤ ម.ម
- រំយោលសង្វាង ប្រវែងទី១ : ១៦ ម.ម ទី២ : ១៤ ម.ម ទី៣ : ១២ ម.ម
- ជើងពានផ្នែកខាងក្រោមមានរាងដូចស្លែងក្របី បណ្តោយប្រវែង ៣៤ ម.ម ទទឹង ៦ ម.ម អក្សរកំពស់ ៤ ម.ម
- សញ្ញាដាក់លើស្បែកសំរាប់ពាក់នឹងឡេវហោប៉ៅអាវស្តាំ ប្រវែងស្បែកពីលើមកក្រោម ១០០ ម.ម

**២. សញ្ញាកងឯកទេសឆ័ត្រយោងមាន ៦ប្រភេទ :**

**១. ផ្លាកសញ្ញាជំនាញឆ័ត្រយោងខ្សែទឹក** (Static line )

សញ្ញានេះផលិតអំពីលោហធាតុ សំរាប់យោធិន ដែលបានឆ្លងកាត់វគ្គហ្វឹកហ្វឺនឆ័ត្រយោង ចប់ជាស្ថាពរ ពាក់នៅលើហោប៉ៅអាវស្តាំ ។ សញ្ញានេះសំរាប់ដាក់លើសញ្ញាប័ត្រឆ័ត្រយោង ។

**២. ផ្លាកសញ្ញាជំនាញឆ័ត្រយោងយោធាចារ្យ** (Jump Master):

រូបសញ្ញានេះផលិតអំពីលោហធាតុ សំរាប់យោធាចារ្យឆ័ត្រយោង ពាក់នៅលើហោប៉ៅអាវស្តាំ ។ សញ្ញានេះសំរាប់ដាក់លើសញ្ញាប័ត្រឆ័ត្រយោងយោធាចារ្យ ។

**៣. ផ្លាកសញ្ញាជំនាញឆ័ត្រយោងបញ្ចា** (Tree Fall):

រូបសញ្ញានេះផលិតអំពីលោហធាតុ សំរាប់យោធិន និងយោធាចារ្យឆ័ត្រយោង ដែលបានឆ្លងកាត់វគ្គហ្វឹកហ្វឺនឆ័ត្រយោងបញ្ចា ចប់ជាស្ថាពរ ពាក់នៅលើហោប៉ៅអាវខាងស្តាំ ។ សញ្ញានេះសំរាប់ដាក់នៅលើសញ្ញាប័ត្រឆ័ត្រយោងបញ្ចា ។

**៤. ផ្លាកសញ្ញាកុម្មង់ដូ** (Commando ) :

រូបសញ្ញានេះផលិតអំពីលោហធាតុ សំរាប់យោធិន ដែលបានឆ្លងកាត់វគ្គហ្វឹកហ្វឺនកុម្មង់ដូ ចប់ជាស្ថាពរ ពាក់នៅលើហោប៉ៅអាវស្តាំ ។ សញ្ញានេះសំរាប់ដាក់នៅលើសញ្ញាប័ត្រកុម្មង់ដូ ។

**៥. ផ្លាកសញ្ញាកងទ័ពពិសេសឆ័ត្រយោង :**

រូបសញ្ញានេះផលិតអំពីក្រណាត់ប៉ាក់ជាអក្សរ (**កងទ័ពពិសេស**) ប៉ាក់ពណ៌ក្រហម និងអក្សរ (**ឆ័ត្រយោង**) ប៉ាក់ពណ៌លឿង សំរាប់ប្រើលើឯកសណ្ឋានលេខ ២-៣-៤ ។ ចំពោះឯកសណ្ឋានលេខ ៥ អក្សរ (**កងទ័ពពិសេស**) ប៉ាក់ពណ៌ខ្មៅ និងអក្សរ (**ឆ័ត្រយោង**) ប៉ាក់ពណ៌ខៀវ ។ ផ្លាកសញ្ញានេះសំរាប់ពាក់នៅដើមដៃខាងស្តាំ នៅពីលើសញ្ញាកងយោធពលខេមរភូមិន្ទ ។

**៦. ផ្លាកសញ្ញាជំនាញឯកទេសមុជទឹក** (Scuba-diving ) :

រូបសញ្ញានេះផលិតអំពីលោហធាតុ សំរាប់យោធិន ដែលបានឆ្លងកាត់វគ្គហ្វឹកហ្វឺនទ័ពពិសេសក្នុងផ្ទៃទឹក ចប់ជាស្ថាពរ ពាក់នៅលើហោប៉ៅអាវខាងស្តាំ ។ សញ្ញានេះសំរាប់ដាក់នៅលើសញ្ញាប័ត្រទ័ពពិសេស ក្នុងផ្ទៃទឹក ។

ចំពោះរូបភាព និងខ្នាតនៃផ្លាកសញ្ញា ទ័ពពិសេសឆ័ត្រយោងទាំង ៦ប្រភេទនេះ មានរូបភាព និងខ្នាត ដូចមានក្នុងឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យនេះ ។

**៣. ឯកសណ្ឋានការងារ** (លេខ៤) : គំរូឯកសណ្ឋាននេះមានពីរសំរាប់គឺ ÷

**១. ឯកសណ្ឋានការងារដៃខ្លី :**

- ឯកសណ្ឋានការងារដៃខ្លី អាវពណ៌គ្រែអ៊ីកាត់ស្រុងដាក់ក្នុងខោ ហើយខោពណ៌គ្រែអ៊ី
- អាវដៃខ្លី ពណ៌គ្រែអ៊ី កខុប ប៊ូលស្មាសងខាង កាត់ស្រុងវែងដាក់ក្នុងខោ ហោប៉ៅពីរដេរប៉ះចំកណ្តាល ដេរបត់ផ្នត់មានគំរបរាងស្លឹកពោធិ ឡេវធម្មតាពណ៌គ្រែអ៊ី
- ខោជើងវែង (ដូចឯកសណ្ឋានលេខ៣ ) ពណ៌គ្រែអ៊ី
- មួកបេរេពណ៌គ្រែអ៊ី នៅស្រទាប់មួកមានចំពណ៌មាសតាមបណ្តោយទំហំ ៨ ម.ម

ᨓ ৮

- ខ្សែក្រវ៉ាត់តូចពណ៌ត្រែអ៊ី (ដូចខ្សែក្រវ៉ាត់ឯកសណ្ឋានលេខ១)

**៣. ឯកសណ្ឋានការងារដៃវែង :**

- ឯកសណ្ឋានការងារដៃវែង មានរូបភាពនិងម៉ូត ដូចឯកសណ្ឋានការងារដៃខ្លីខាងលើ តែមានដៃវែង នៅចុងដៃ អាវមានឆែក និងដាក់ឡេវ ។
- ខោ មួក ដូចឯកសណ្ឋានការងារដៃខ្លី ។
- ចំពោះនារី អាវដូចបុរស ខោជើងវែងកាត់ដូចបុរស ឡេវចំហៀង ឬសំពត់ហ្ស៊ីបមានឆែកពីក្រោយពណ៌ត្រែអ៊ី ក្រោមជង្គង់ ។

* ឯកសណ្ឋានការងារ(លេខ៤)នេះ សំរាប់ពាក់ធ្វើការងារធម្មតាក្នុងការិយាល័យ ឬក្នុងបន្ទាយ និងទំនាក់ទំនងការងារធម្មតា ។

**គ្រឿងសម្គាល់** : ពាក់អាវដៃខ្លី ឬដៃវែងពណ៌ត្រែអ៊ី នៅដៃអាវខាងស្តាំដាក់ផ្លាកកងយោធពលខេមរភូមិន្ទ និងនៅដៃអាវខាងឆ្វេងពាក់ផ្លាកកងឯកភាព(បើមាន) ។ ខោជើងវែងពណ៌ត្រែអ៊ី ខ្សែក្រវ៉ាត់តូចពណ៌ត្រែអ៊ី មួកបេរេពណ៌ត្រែអ៊ី មានរូបព្រះសង្ហានៅខាងមុខផ្នែកខាងស្តាំ និងមានសញ្ញាសក្តិនៅខាងមុខផ្នែកខាងឆ្វេង ស្បែកជើងស្បែកកខ្លីពណ៌ខ្មៅ និងស្រោមជើងខ្មៅ ។ ពាក់សញ្ញាប្រភេទទ័ពនៅកអាវ ផ្លាកឈ្មោះនៅខាងលើហោប៉ៅអាវស្តាំ ហានុមានពាក់នៅនឹងឡេវហោប៉ៅអាវស្តាំ សក្តិនៅលើស្មាដែលមានហ្វូងសក្តិខ្មៅក្បាលស្រួច និងពាក់ក្បាលមេដាយ (បើមាន) អាវជានិច្ចកាលត្រូវដាក់ក្នុងខោ ។ ចំពោះកងនាវាចរ និងអាកាសចរ ត្រូវស្លៀកពាក់ឯកសណ្ឋានការងារ តាមការកំណត់ខាងលើ ហើយពាក់គ្រឿងរួមផ្សេងៗទៀត និងរបៀបប្រើប្រាស់ដូចទ័ពជើងគោក តែកងអាកាសចរ និងបណ្តាកងឯកភាព ដែលមានសញ្ញាលើហោប៉ៅអាវស្តាំ លើផ្លាកឈ្មោះ ត្រូវពាក់ថែមទៀត ។

ចំពោះរូបភាពនៃឯកសណ្ឋានការងារដៃខ្លីនិងដៃវែងមានគំរូក្នុងឧបសម្ព័ន្ធទី ៣ នៃអនុក្រឹត្យនេះ ។

**៤. មួកបេរេ :**

- ថ្នាក់ឧត្តមសេនីយ៍ មួកបេរេ ពណ៌ត្រែអ៊ី មានចំពណ៌មាស តាមបណ្តោយស្រទាប់មួក ទំហំ ៨ ម.ម
- ថ្នាក់វរសេនីយ៍ មួកបេរេ ពណ៌ត្រែអ៊ី មានចំពណ៌ក្រហម តាមបណ្តោយស្រទាប់មួក ទំហំ ៥ ម.ម
- ថ្នាក់អនុសេនីយ៍ មួកបេរេ ពណ៌ត្រែអ៊ី មានចំពណ៌ទឹកប្រាក់ តាមបណ្តោយស្រទាប់មួក ទំហំ ៥ ម.ម

នៅខាងមុខមួកបេរេ ផ្នែកខាងស្តាំមានរូបព្រះសង្ហា ផលិតអំពីលោហធាតុពណ៌មាស នៅខាងមុខមួកផ្នែកខាងឆ្វេង មានសញ្ញាសក្តិ ។

ថ្នាក់ឧត្តមសេនីយ៍ សញ្ញាសក្តិ (ផ្កាយ) មានកំពស់ ១៤ ម.ម ផលិតអំពីលោហធាតុពណ៌មាសតម្រៀបគ្នាដូចសក្តិស្មា ។

ថ្នាក់វរសេនីយ៍ និងថ្នាក់អនុសេនីយ៍ សញ្ញាសក្តិចាក់អំពីក្រណាត់មានទំហំបណ្តោយ ៣៥ ម.ម ទទឹង ២៨ ម.ម ។

ចំពោះរូបភាពនៃមួកបេរេ មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៤ នៃអនុក្រឹត្យនេះ ។

**៥. សញ្ញាអត្តសញ្ញាណ :**

សញ្ញាអត្តសញ្ញាការប្រភេទ ១ ដែលមានរូបភាពនិងខ្នាត ត្រូវបានកំណត់ដូចតទៅ ÷

**សញ្ញាអគ្គបញ្ជាការ ប្រភេទ ១ :** មានរាងពងក្រពើ គ្មានហ្វុងនៅពីក្រោយ ដែលមានកំពស់ប្រវែង ៤៤ ម.ម បណ្តោយ ៤៧ ម.ម នៅជុំវិញមានរចនាលំអរដោយកួរស្រូវពីរកោងរាងស្លែងក្របី ដែលតំណាងឱ្យប្រជារាស្ត្រ។ នៅចំកណ្តាលមានផ្កាយពណ៌មាសនិងខៀវ មានជ្រុងប្រាំបី ដែលតំណាងឱ្យឫទ្ធីបារមីទិសទាំងប្រាំបី ។ នៅចំកណ្តាលផ្កាយ មានផ្ដិប្រសព្វដោយរូបលំពែងត្រីសូល្យ ក្រោមរូបម្កុដរាជ្យដែលមានកាំរស្មីប្រាំពីរ ស្លាបសត្វហង្ស និងយុទ្ធាពណ៌មាស ដែលតំណាងឱ្យកងទ័ពទាំងបីប្រភេទ ។

រូបសញ្ញានេះផលិតពីលោហធាតុ សំរាប់ពាក់នៅលើហោប៉ៅអាវស្តាំ ពីលើផ្លាកឈ្មោះ នៃឯកសណ្ឋាន លេខ ២-៣-៤ ។ សញ្ញានេះសំរាប់ដាក់នៅលើក្បាលលិខិត នាមប័ណ្ណ វត្ថុអនុស្សាវរីយ៍ អគ្គបញ្ជាការដ្ឋាន និង អង្គភាពចំណុះផ្ទាល់ ។

រូបភាព នៃសញ្ញាអគ្គបញ្ជាការ ប្រភេទទី ១ មានគំរូក្នុងឧបសម្ព័ន្ធទី ៥ នៃអនុក្រឹត្យនេះ ។

## ៦. សញ្ញាកងទ័ពជើងគោក :

សញ្ញាកងទ័ពជើងគោក ប្រភេទ ១ ដែលមានរូបភាព និងខ្នាត ត្រូវបានកំណត់ដូចតទៅ ÷

**សញ្ញាកងទ័ពជើងគោក ប្រភេទ ១ :** មានរាងពងក្រពើ ពណ៌ទឹកមាស ពណ៌ស ដែលមានកំពស់ ៤៨ ម.ម បណ្តោយប្រវែង ៥០ ម.ម ។ នៅខាងក្រោមចំកណ្តាលមានក្បាច់ដកចន្ទនី និង មានកួរស្រូវព័ទ្ធជុំវិញជារង្វង់ស្លែងក្របី ។ នៅចំកណ្តាល មានទង់ជាតិដែលមានរាងជារំខែល និងមានរូបប្រាសាទអង្គរ ។ រូបម្កុដរាជ្យមានកាំរស្មីប្រាំពីរពីលើរូបលំពែងត្រីសូល្យពណ៌មាស ។ ដាវនិងកាំភ្លើងពណ៌មាស ដាក់ខ្វែងគ្នាតំណាងឱ្យកងទ័ពជើងគោក ។

រូបសញ្ញានេះផលិតពីលោហធាតុ សំរាប់ពាក់នៅលើហោប៉ៅអាវស្តាំ ពីលើផ្លាកឈ្មោះ នៃឯកសណ្ឋាន លេខ ២-៣-៤ ។ សញ្ញានេះសំរាប់ដាក់លើក្បាលលិខិត នាមប័ណ្ណ វត្ថុអនុស្សាវរីយ៍ បញ្ជាការដ្ឋានកងទ័ពជើងគោក និងអង្គភាពចំណុះ ។

រូបភាព នៃសញ្ញាកងទ័ពជើងគោក ប្រភេទទី ១ មានដូចក្នុងឧបសម្ព័ន្ធទី ៦ នៃអនុក្រឹត្យនេះ ។

## ៧. សញ្ញាកងទ័ពជើងទឹក :

សញ្ញាកងទ័ពជើងទឹក ប្រភេទ ១ ដែលមានរូបភាពនិងខ្នាត ត្រូវបានកំណត់ដូចតទៅ ÷

**សញ្ញាកងទ័ពជើងទឹក ប្រភេទ ១ :** មានរាងជាទឹករលកពីរជាន់តំណាងផ្ទៃសមុទ្រ ដែលមានកំពស់ ៤៦ ម.ម និងបណ្តោយ ៧០ ម.ម ។ នៅចំកណ្តាលទឹករលកមានរូបម្កុដរាជ្យ ដែលមានកាំរស្មីប្រាំពីរ និងរូបយុទ្ធាដែលតំណាងឱ្យកងទ័ពជើងទឹក ។

រូបសញ្ញានេះផលិតពីលោហធាតុ សំរាប់ពាក់នៅលើហោប៉ៅអាវស្តាំ ពីលើផ្លាកឈ្មោះ នៃឯកសណ្ឋាន លេខ ២-៣-៤ ។ សញ្ញានេះសំរាប់ដាក់លើក្បាលលិខិត នាមប័ណ្ណ វត្ថុអនុស្សាវរីយ៍ បញ្ជាការដ្ឋានកងទ័ពជើងទឹក និងអង្គភាពចំណុះ ។

រូបភាព នៃសញ្ញាកងទ័ពជើងទឹក ប្រភេទទី ១ មានដូចក្នុងឧបសម្ព័ន្ធទី ៧ នៃអនុក្រឹត្យនេះ ។

**៨. សញ្ញាកងទ័ពជើងអាកាស :**

សញ្ញាកងទ័ពជើងអាកាសមាន ១ប្រភេទ ដែលមានរូបភាពនិងខ្នាត ត្រូវបានកំណត់ដូចតទៅ ÷

រូបស្លាបសត្វបាងុរដែលជានិមិត្តសញ្ញាកងទ័ពជើងអាកាស មានកំពស់ ៤៣ ម.ម និងបណ្តោយ ៨០ ម.ម ។ នៅចំកណ្តាលស្លាបសត្វបាងុរខាងលើ មានរូបមកុដរាជ្យ មានកាំរស្មីធំប្រាំពីរ កាំរស្មីតូចប្រាំពីរ ផ្នែកខាងក្រោម មានទង់ជាតិ នៃព្រះរាជាណាចក្រកម្ពុជា ដែលមានរាងដូចខែល ។

រូបសញ្ញានេះផលិតពីលោហធាតុ សំរាប់ពាក់នៅលើហោប៉ៅអាវស្តាំ ពីលើផ្លាកឈ្មោះ នៃឯកសណ្ឋាន លេខ ២-៣-៤ ។ សញ្ញានេះសំរាប់ដាក់លើក្បាលលិខិត នាមប័ណ្ណ វត្ថុអនុស្សាវរីយ៍ បញ្ជាការដ្ឋានកងទ័ពជើងអាកាស និងអង្គភាពចំណុះ ។

រូបភាព នៃសញ្ញាកងទ័ពជើងអាកាស មានដូចក្នុងឧបសម្ព័ន្ធទី ៨ នៃអនុក្រឹត្យនេះ ។

**៩. រូបសញ្ញាក្រសួងការពារជាតិ :**

រូបសញ្ញានេះផលិតពីលោហធាតុ ត្រូវបានពាក់នៅលើហោប៉ៅអាវឆ្វេង នៃឯកសណ្ឋានលេខ ២-៣-៤។ សញ្ញានេះសំរាប់ដាក់នៅ លើក្បាលលិខិត នាមប័ណ្ណ វត្ថុអនុស្សាវរីយ៍ ទីស្តីការក្រសួងការពារជាតិ និង អង្គភាពចំណុះផ្ទាល់ ។

រូបភាព នៃសញ្ញាក្រសួងការពារជាតិ ត្រូវបានកំណត់ដូចក្នុងឧបសម្ព័ន្ធទី ៩ នៃអនុក្រឹត្យនេះ ។

**មាត្រា ២._**

ក្រសួងការពារជាតិ និងអគ្គបញ្ជាការដ្ឋាន មានសិទ្ធិចេញសេចក្តីប្រកាស ក្នុងការបង្កើតសញ្ញាសំគាល់ឱ្យ បណ្តាស្ថាប័ន និងកងឯកភាពចំណុះ ។

**មាត្រា ៣._**

មាត្រា៥ ចំណុចខ២ មាត្រា៦ ចំណុចទី២១ នៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ១៩៩៧ មាត្រា១ ចំណុចក៤ មាត្រា៤ ចំណុចទី៤ នៃអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០០០ មាត្រា ១ ចំណុច ក១ - ខ១ - គ១ - ឃ១ - ង នៃអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០០១ និង បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤.-**

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ និងក្រសួងពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមអនុក្រឹត្យនេះ ដោយចូលជាធរមាន ចាប់ពីថ្ងៃ ដែលបានចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**បានយកសេចក្តីជំរាបជូន សម្តេចនាយករដ្ឋមន្ត្រី**

**សហរដ្ឋមន្ត្រីក្រសួងការពារជាតិ**

**ទៀ បាញ់** **ស៊ីសុវត្ថិ សិរីរ័ត្ន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យលេខ ៤៥ អនក្រ.បក
## ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៣
## ស្តីពីផ្លាកសញ្ញារូបហនុមាន



# ឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យលេខ ៤៤.អនក្រ.បក
## ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៣
## ស្តីពីសញ្ញាកងឯកភាពឆ័ត្រយោង

**ឯកសណ្ឋានការងារ** | **ឯកសណ្ឋានប្រយុទ្ធ**

១. ផ្លាកជំនាញឆ័ត្រយោងស្វាធិក ៧០មម × ២៥មម




២. ផ្លាកជំនាញឆ័ត្រយោងយោធាចារ្យ ៧០មម × ៣០មម




៣. ផ្លាកជំនាញឆ័ត្រយោងបញ្ជា ៧០មម × ៣០មម




៤. ផ្លាកជំនាញកម្មង់ដូ ៤៥មម × ៥២មម




៥. ផ្លាកជំនាញកម្មង់ដូឆ័ត្រយោង ៧០មម × ៣០មម




៦. ផ្លាកជំនាញឯកទេសមុជទឹក ៤៥មម × ៥២មម




## ឧបសម្ព័ន្ធទី៣ នៃអនុក្រឹត្យលេខ ៤៥.អនក្រ.បក
## ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៣
## ស្តីពីឯកសណ្ឋានការងារដៃខ្លី និង ដៃវែង





# ឧបសម្ព័ន្ធទី៤ នៃអនុក្រឹត្យលេខ.៤៥.អនក្រ.បក

ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០០៣

## ស្តីពីមួក ឆោណេ



## ឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យលេខ ៤៤ អនក្រ.បក
## ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៣
## ស្តីពីផ្លាកសញ្ញាកងទ័ពជើងគោក

### ប្រភេទ ១



## ឧបសម្ព័ន្ធទី៥ នៃអនុក្រឹត្យលេខ ៤៥ អនក្រ.បក

ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៣

## ស្តីពីផ្លាកសញ្ញាអង្គបញ្ជាការ

**ប្រភេទ ១**



## ឧបសម្ព័ន្ធទី៧ នៃអនុក្រឹត្យលេខ ៥៥ អនក្រ.បក
## ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៣
## ស្តីពីផ្លាកសញ្ញាកងទ័ពជើងទឹក

### ប្រភេទ ១



ឧបសម្ព័ន្ធទី៨ នៃអនុក្រឹត្យលេខ..៤៥..អនក្រ.បក

ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៣

ស្តីពីសញ្ញាគងទ័ពជើងអាកាស



## ឧបសម្ព័ន្ធទី៥ នៃអនុក្រឹត្យលេខ.៤៥.អនក្រ.បក
## ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៣
## ស្តីពីផ្លាកសញ្ញាក្រសួងការពារជាតិ

